ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ០៤.០៦១/០៨ គ.ជ.ប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៨

# អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ ២០០៧ មានចំនួន ៨.១២៤.៣៩១ នាក់

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប) បានសម្រេចបន្ថែមឈ្មោះអ្នកបោះឆ្នោតចំនួន ៣២១នាក់ ទៀត ក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០០៧ ដែលធ្វើឱ្យអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុប ចំនួន **៨.១២៤.៣៩១** នាក់ ។

ករណីនេះត្រូវបាន គ.ជ.ប ធ្វើការសម្រេចកាលពីថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០០៨ ។ ឈ្មោះអ្នកបោះឆ្នោតដែលត្រូវបានបញ្ចូលក្នុងបញ្ជីបោះឆ្នោតនោះមាននៅក្នុងខេត្ត ក្រុង ចំនួន ៤ គឺ ក្រុងភ្នំពេញ មានចំនួន ៣១៨ នាក់ ខេត្តបន្ទាយមានជ័យ ចំនួន ១ នាក់ ខេត្តតាកែវ ចំនួន ១ នាក់ និងក្រុងព្រះសីហនុ ចំនួន ១ នាក់ ។ ជាមួយគ្នានេះ គ.ជ.ប ក៏បានកែតម្រូវឈ្មោះ ចំនួន ១ នាក់ និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ចំនួន ២២ នាក់ នៅក្រុងភ្នំពេញ ។

ឯកឧត្តម **មាន សទិ** សមាជិក គ.ជ.ប បានមានប្រសាសន៍បញ្ជាក់ពីមូលហេតុខាងលើ នៅក្នុងសន្និសីទសារព័ត៌មាន គ.ជ.ប កាលពីថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០០៨ ថា ថ្មីៗនេះ គ.ជ.ប បានធ្វើសវនកម្មផ្ទៃក្នុងមួយលើបញ្ជីបោះឆ្នោតឆ្នាំ ២០០៧ ដោយធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ លើបណ្តឹង លើបញ្ជីបោះឆ្នោតដំបូង។ ក្នុងការត្រួតពិនិត្យ គ.ជ.ប បានរកឃើញនូវឯកសារមួយចំនួននៃខេត្ត ក្រុងចំនួន ៤ ដែលមិនត្រូវបានបញ្ចូល លុប និង កែតម្រូវក្នុងបញ្ជីបោះឆ្នោត ។

ឯកឧត្តម បានបញ្ជាក់ថា នេះជាកំហុសបច្ចេកទេស ហើយ គ.ជ.ប ក៏បានកែតម្រូវឡើងវិញរួចរាល់ផងដែរ ដើម្បីជៀសវាងការបាត់បង់សិទ្ធិអ្នកបោះឆ្នោត ។